គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP
IDA - KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - PDP- PJJ - VIGILANCE
#9, St.330, Boeng Keng Kong III, Chamcar Morn, P.P Tel/Fax: (023) 218 759, Tel: 30 14 15, E-mail: chrac@forum.org.kh, chracsecretariat@yahoo.com

# សេចក្ដីថ្លែងការណ៍

## ការគាំទ្រលើលិខិតចំហររបស់ក្រុមសមាគមអ្នកកាសែត ចំពោះការសុំព្រះរាជប្រទានការលើកលែងទោស ដល់លោក ហង្ស ចក្រា ចាងហ្វាងកាសែតខ្មែរម្ចាស់ស្រុក

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ពន្ធ័អង្គការ-សមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុក ចំនួន ២១ សូមសំដែងនូវការកោតសរសើរ និង គាំទ្រចំពោះគំនិតនៅក្នុងលិខិតចំហររបស់តំណាងសមាគមអ្នកកាសែត អង្គការមិនមែនរដ្ឋាភិបាល និង ស្ថាប័នពតិមាននានា ដែលបានក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការដ៏ខ្ពង់ខ្ពស់បំផុត កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ដើម្បីស្នើសុំលើកលែងទោស ចំពោះលោក **ហង្ស ចក្រា** ចាងហ្វាងកាសែតខ្មែរម្ចាស់ស្រុក ។

លោក **ហង្ស ចក្រា** ត្រូវបានសាលាដំបូងរាជធានីភ្នំពេញសំរេចដាក់ទោសលោកឱ្យជាប់ពន្ធនាគារចំនួន ១ ឆ្នាំ និង ពិន័យជាប្រាក់ចំនួនប្រាំបួនលានរៀល ដោយគិតចាប់ពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ពីបទ "*បរិហារកេរ្តិ៍ និង ផ្សព្វផ្សាយពតិមានមិនពិត*" ហើយមកដល់បច្ចុប្បន្ននេះ លោក **ហង្ស ចក្រា** កំពុងជាប់ឃុំនៅក្នុងពន្ធនាគារព្រៃសរនៅឡើយ ។

គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា ការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិធ្វើឡើងដោយលោក **ហង្ស ចក្រា** មិនបានបង្ករឱ្យខូចខាតដល់សណ្តាប់ធ្នាប់ និង សន្តិសុខសង្គម ជាធំដុំទេ។ ដូច្នេះ ការចេញសាលក្រមដាក់ទោសដោយតុលាការអំពីការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិអំពីបញ្ហាជាតិរបស់លោក **ហង្ស ចក្រា** គួរតែទទួលបាននូវការប្រោសប្រណីលើកលែងទោសពីព្រះមហាក្សត្រ ។

យោងតាមលិខិតរបស់ក្រុមសមាគមអ្នកសារពតិមានបានឱ្យដឹងថា ស្ថានភាពសុខភាពរបស់លោក **ហង្ស ចក្រា** កំពុងតែទ្រុឌទ្រោម ដែលទាមទារឱ្យមានការព្យាបាលជំងឺប្រកបដោយការយកចិត្តទុកដាក់ ម្យ៉ាងទៀតគ្រួសាររបស់លោកកំពុងមានជីវភាពក្រីក្រ ដែលមានតែលោកម្នាក់ប៉ុណ្ណោះជាជំហរដ៏រឹងមាំក្នុងការផ្គត់ផ្គង់ដល់ជីវភាពគ្រួសារ ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមអំពាវនាវផងដែរដល់ក្រសួងយុត្តិធម៌ និងរាជរដ្ឋាភិបាលកម្ពុជា មេត្តាជួយសំរួលតាមនិតិវិធី ដើម្បីថ្វាយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ដើម្បីព្រះអង្គមានភាពងាយស្រួលក្នុងការព្រះរាជប្រទានការលើកលែងទោសដល់លោក **ហង្ស ចក្រា** ឱ្យមានសេរីភាពឡើងវិញ និង បានវិលត្រឡប់ទៅជួបជុំគ្រួសារដោយសេចក្តីអនុគ្រោះ ។

ភ្នំពេញ, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩

☏ *សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:*

| | | |
|---|---|---|
| -លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| -លោក **ធន សារាយ** | ប្រធានសមាគមអាដហុក ADHOC | ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩ |
| -លោក **សុក សំអឿន** | នាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| -លោកស្រី **សយ វឌ្ឍនី** | នាយិកាប្រតិបត្តិ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ CWCC | ទូរស័ព្ទលេខ: ០៩២ ៩៩៣ ៣៥៨ |
| -លោកស្រី **ស៊ុន ចាន់សែន** | ប្រធានសមាគមយុវជនខ្មែរ KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |